# ៥~ រឿង ពាក្យសុភាសិតតម្លៃ៣០តម្លឹង

កាលពីព្រេងនាយមានជនពីរនាក់ប្ដីប្រពន្ធ បុរសជាប្ដីបានឃើញ គេរៀនរបៀនពូកែ ចង់រៀនណាស់យកប្រាក់៣០តម្លឹងលាប្រពន្ធដើរទៅរករៀន ដើរពីស្រុកមួយដល់ខែត្រមួយ ឮគេថាត្រង់ណាមានអ្នកចេះរបៀនអាគមគាថាពូកែ ក៏ទៅរកត្រង់នោះ ដល់ទៅជួបគ្រូណាពូកែគេសូត្រឲ្យស្ដាប់ គេធ្វើឲ្យមើលដូចម្ដេចៗ ក៏ចេះតែមិនចូលចិត្តលុះដើរឆ្ងាយទៅ ក៏បានជួបនឹងតាចាស់ម្នាក់ ។ តាចាស់សួរថា "អ្នកឯងទៅណាដើរមកតែម្នាក់ឯងស្វះស្វែងរកអ្វី ?" ។ បុរសនោះឆ្លើយថា "ឪ! តាអើយ! ខ្ញុំមកនេះដ្បិតឮគេថានៅទីនេះមានគ្រូចេះរបៀនពូកែ បានជាខ្ញុំខំសង្វាតមក ក្រែងតាចេះដឹង ប្រដៅចៅផង" ។ តាចាស់ឆ្លើយថា "តាមានរបៀនបីបទតំលៃ៣០តម្លឹង បើអ្នកឯងកាន់ជាប់ អ្នកឯងមិនច្បុតទេគង់បានដូចចិត្ត បើមានកិច្ចដំណើរអ្វីឲ្យសូត្ររបៀនតានេះចុះពូកែណាស់" ។ បុរសនោះថា "តាសូត្រឲ្យខ្ញុំស្ដាប់មើល! បើចូលចិត្តខ្ញុំយក" ។ តានោះសូត្រឲ្យស្ដាប់ថា "រពិសដៃផ្ទៃឆ្អែត ដេកយប់កុំនិយាយនឹងស្រី ឃ្លានកុំអាលស៊ី" ។ បុរសនោះស្ដាប់បានចូលចិត្តក៏ប្រគល់ប្រាក់៣០តម្លឹងឲ្យតានោះ ហើយទន្ទេញរបៀនទាំងបីបទនោះចាំស្ទាត់រត់មាត់ ។ ឯតាចាស់ប្រាប់ថា "បើចៅកាន់របៀនទាំងបីម៉ាត់នេះបាន តាឲ្យទទេ មិនយកតម្លៃទេ" ហើយតាចាស់ប្រគល់ប្រាក់ឲ្យបុរសនោះវិញ ។ បុរសនោះលាតាចាស់នោះវិលមកស្រុកវិញ ។ មាត់បុរសនោះចេះតែទន្ទេញរបៀនបីបទនោះចប់តាមផ្លូវមកពុំមានភ្លេច ។ លុះដើរឆ្ងាយបន្តិចមកជួបនឹងសំពៅឈ្មួញមួយ បុរសនោះក៏សុំដោយសារសំពៅគេមកស្រុក ដង្ហោសំពៅក៏ឲ្យដោយសារ បុរសនោះតាំងពីចុះមកនៅក្នុងសំពៅថ្ងៃណា ក៏ចេះតែទន្ទេញរបៀនបីបទនោះ ហើយចេះតែជួយលាងជួយថែទាំ ជួយជូតជុលសំពៅដូចជារបស់ខ្លួន ។ នាយសំពៅនឹកក្នុងចិត្តថា "អ្នកនេះតាំងតែពីចុះមក ដោយសារសំពៅអញកាលណា គាត់ចេះថែធ្វើការដូចជារបស់គាត់" នឹកហើយក៏ស្រឡាញ់បុរសនោះ ឲ្យរៀបបាយទឹកឲ្យស៊ីតែរាល់ថ្ងៃរៀងមក ។ ឯបុរសនោះពុំខ្ជិលសោះ ចេះតែខំធ្វើការក្នុងសំពៅដូចជាកូនឈ្នួលឯទៀតៗ ។ នាយសំពៅនឹកតែក្នុងចិត្តថា "បើកាលណាបានដល់ស្រុកអញនឹងចែករបស់ទ្រព្យឲ្យចៅនោះរកស៊ីតទៅ" ។ លុះបើកសំពៅមកដល់កណ្ដាលស្រុកមួយ បានឃើញវិហារមួយគេរៀប អណ្ដាប់ពោរពាសសុទ្ធតែចំណីស្រាបាយទុកឲ្យយក្សវាស៊ី ។

ឯអ្នកសំពៅកាលដល់វិហារនោះ ក៏ចតសំពៅឡើងលេង ឃើញចំណីទាំងនោះពុំមានមនុស្សក៏នាំគ្នាស៊ីផឹកស្រាស្រវឹង ដេកនៅក្នុងវិហារនោះទាំងអស់គ្នា ខានតែបុរសម្នាក់នោះមាត់គាត់ចេះតែទន្ទេញថា "រពិសដៃផ្ទៃឆ្អែត ដេកយប់កុំនិយាយនឹងស្រី ឃ្លានកុំអាលស៊ី" ដោយគិតថា "ចំណីទាំងអស់នេះមានហេតុអ្វីមួយហើយបានជាគេរៀបទុកនៅទីនេះ ឥឡូវអ្នកទាំងអស់នេះស៊ីគង់តែមានភ័យពុំខាន" គិតដូច្នោះហើយពុំហ៊ានស៊ីឡើយទៅពួនលើធ្នឹមវិហារដោយស្ងៀមស្ងាត់លបមើល ។

លុះដល់ថ្ងៃត្រង់ យក្សមកដល់ហើយវាខឹងណាស់ថា "នរណាក៏ហ៊ានមកស៊ីចំណីអស់នេះ គេរៀបទុកឲ្យតែអញស៊ីទេ ឥឡូវវាស៊ីអស់ហើយវាដេកនៅទីនោះ" ។ យក្សថាហើយក៏បោះដំបងទៅវាយមនុស្សដែលដេកនោះស្លាប់ទាំងអស់ទៅ ។ ឯដំបងក៏វិលមកខាង យក្សវិញ ហើយយក្សក៏កាច់កមនុស្សទាំងអស់នោះស៊ីទៅរួចក្រឡេកមើលក្រឡេមក្រឡឹម ។ បុរសឃើញយក្សភ័យណាស់ មាត់ចេះតែទន្ទេញរបៀនបីបទហើយគិតថា "បើអញស្រែកក្រែងយក្សវាឮ វាឃើញអញហើយវានឹងស៊ីអញទៀត" ។ គិតហើយក៏លោតពីលើធ្នឹម ស្រែកវ៉ាសឡើង ។ យក្សភ័យណាស់ក៏រត់ចោលដំបងទៅបាត់ទៅ ។ បុរសនោះបានដំបងវាយឯងហើយក៏ដើរត្រឡប់មកស្រុក ចោលសំពៅនៅកំពង់វិហារនោះឯង ។

លុះដើរមកដល់ផ្ទះក្នុងវេលាយប់ បុរសនោះយកដំបងទៅលាក់ក្រោមជណ្ដើរយកថ្មសង្កត់លើហើយឡើងទៅដេកលើផ្ទះ ។ ប្រពន្ធសួរប្រាប់ប្រពន្ធថា "ចាំព្រឹកសឹមនិយាយប្រាប់" ។

ក្រោយពេលប្ដីទៅ ប្រពន្ធនៅផ្ទះវាមានសហាយ វេលាយប់ដែលប្ដីមកដល់ផ្ទះ សហាយនោះវាមកស្ដាប់នៅក្រោមផ្ទះ វាចង់ដឹងរឿងឆាប់ឲ្យមេស្រីសហាយវាសួរថា "ដំណើរដូចម្ដេចក៏ចាំព្រឹកបាននិយាយ ?" ។ ប្រពន្ធចេះតែអោបអង្អែលៗទ្រាំពុំបានប្ដីក៏និយាយប្រាប់ថា "អញនិយាយនឹងឯងនេះខុសគ្រូហើយដ្បិតគ្រូផ្ដាំថា : ដេកយប់កុំនិយាយនឹងស្រី ឥឡូវនេះអញនិយាយខុសបណ្ដាំគ្រូហើយ" ។ ប្រពន្ធសួរថា "អ្នកទៅបានរបស់អ្វីមកខ្លះ ?" ។ ប្ដីថា "បានតែរបៀនបីបទហើយត្រឡប់មកវិញ ដល់ពាក់កណ្ដាលផ្លូវបានដំបងវាយឯង" ។ ប្រពន្ធសួរថា "ដំបងនោះទុកនៅឯណាឥឡូវនេះ ? ខ្ញុំចង់ឃើញ" ។ ប្ដីថា "អញទុកក្រោមជណ្ដើរយកថ្មគ្រប" ថាហើយក៏ដេកលក់ទៅ ។

សហាយលបស្ដាប់ឮហើយក៏ទៅក្រោមជណ្ដើររើសយកដំបងនោះទៅបាត់ទៅ ។

លុះព្រឹកព្រហាមស្រាងៗឡើង បុរសនោះរពួកពីដេកចុះទៅរកដំបងពុំឃើញ ក៏ប្រាប់ប្រពន្ធថា "អញប្រាប់ឯងមិនជឿអញថា ខុសគ្រូហើយ ឯងចេះតែលួងអញ ទាល់តែអញប្រាប់ឥឡូវនេះ មនុស្សវាឮវាលួចយកដំបងបាត់ទៅហើយ" ។ ប្រពន្ធឮហើយដឹងថាសហាយលួច ក៏មិនស្ដីដណ្ដាំបាយឲ្យប្ដីស៊ីៗរួចហើយបុរស នោះក៏យកខ្សែចងដុំថ្មដែលគ្របលើដំបងនោះ នាំទៅប្ដឹងមេស្រុកឲ្យជំនុំ ជម្រះរកចោរឲ្យ មេស្រុកបើជំនុំជម្រះដូចម្ដេចពីព្រោះថ្មពុំចេះស្ដី គេជេរថា "អាកំព្រើល! តាំងពីដូនតាមកនរណាដែលឃើញដំបងវាយឯង"គេគម្រាមហើយគេដេញចេញទៅ ។ បុរសនោះចេះតែអូសថ្មទៅប្ដឹងតាំងតែពីមេស្រុកដល់ទៅលោកយមរាជ អ្នករាជការគ្រប់ក្រសួងគេចេះតែដេញចេញ គេថាមនុស្សឆ្កួត គេមិនឲ្យចូល ។ បុរសនោះអូសថ្មទៅថ្វាយស្ដេចៗ ទ្រង់សួរសព្វគ្រប់ហើយទ្រង់ប្រាប់ អស់នាហ្មឺនថា "មែនបានគេថា មានប្រឡាយបានទឹកហូរមានសម្រាមបានផ្អែវាជុះ អស់នាហ្មឺនកុំថាវាឆ្កួតសេចក្ដីនេះមែនហើយបានជាវាហ៊ានថា" ស្ដេចមានព្រះបន្ទូលប្រាប់បុរសថា "ណ្ហើយវិលទៅផ្ទះចុះកាលណាអញឲ្យគេទៅហៅចាំមក" ។ បុរសនោះទូលថា "ព្រះករុណាថ្លៃវិសេស" ហើយក្រាបថ្វាយបង្គំលាទៅផ្ទះវិញ ។

ក្រោយពេលបុរសនោះទៅ ស្ដេចទ្រង់ព្រះរាជបញ្ជាឲ្យប្រាប់ បណ្ដាប្រជារាស្ត្រថា "ដ្បិតស្ដេចឲ្យអស់ព្រះស្នំចេញរាំបីថ្ងៃបីយប់ឲ្យ បណ្ដារាស្ត្រមើលតាមចិត្ត ពុំមានឃាត់ឃាំងឡើយ" ហើយទ្រង់ឲ្យរៀបលេងល្ខោន ។ កាលនោះអស់រាស្ត្រសឹងតែចូលទៅមើលគ្រប់គ្នា ។ ស្ដេចទ្រង់យាងចូលទៅក្នុងព្រះរាជដំណាក់ជ្រើសរើសប្រេង ក្រអូបយ៉ាងចំឡែកមួយដបដែលសំរាប់តែស្ដេច អស់រាស្ត្រនាហ្មឺនពុំ ដែលមានទ្រង់ប្រើអាមាត្យម្នាក់យកទៅឲ្យបុរសនោះ ហើយប្រាប់ថា "ស្ដេចទ្រង់ព្រះរាជទានឲ្យអ្នកឯងនិងប្រពន្ធអ្នកឯងលាប ប៉ុន្តែឲ្យអ្នកឯងនៅផ្ទះកុំទៅមើលល្ខោនឲ្យតែប្រពន្ធទៅបានហើយ" ។ អាមាត្យអ្នកយកទៅឲ្យប្រាប់សព្វគ្រប់ហើយ វិលទៅក្រាបបង្គំទូលស្ដេចវិញ ។ បុរសនោះបានប្រេងក៏ហៅប្រពន្ធមកហុចប្រេងទៅឲ្យប្រាប់ថា "ព្រះករុណាជាអម្ចាស់ជីវិតទ្រង់ព្រះរាជទានប្រេងនេះមក ព្រោះទ្រង់អាណិតស្រឡាញ់ឲ្យយើងលាបទៅមើលល្ខោននឹងគេតែឥឡូវនេះអញឈឺក្បាល ឯងយកទៅលាប ហើយទៅមើលល្ខោននឹងគេចុះ" ។ ឯប្រពន្ធឮប្ដីបើកឲ្យទៅ ហើយឲ្យទាំងប្រេងទៅលាបផងដូច្នោះអរពន់ពេកដោយពុំបានដឹងកលជាគេនឹងចាប់ ក៏យកប្រេងទៅឲ្យសហាយលាបផង ហើយបណ្ដើរគ្នាទៅមើលល្ខោនឈរទន្ទឹមគ្នា ។ លុះបន្តិចទៅ ស្ដេចទ្រង់ធុំក្លិនក្រអូបប្រេងនោះ ទ្រង់ខ្សឹបប្រាប់នាហ្មឺនម្នាក់ថា "ចូរអ្នកទៅហិតក្លិនប្រេងក្រអូបយ៉ាងនោះ ប៉ុន្មាននាក់ ចូរអ្នកនាំយកមកឲ្យអញជាឆាប់" ។

នាហ្មឺននោះក្រាបថ្វាយបង្គំហើយ ទៅហិតមនុស្សឯទៀតមិនធំ សោះតែប្រុសម្នាក់ ស្រីម្នាក់ ដែលឈរទន្ទឹមគ្នាលាបប្រេងក្រអូបទាំងពីរនាក់នោះ ក៏នាំយកទាំងប្រុសទាំងស្រីយកទៅថ្វាយស្ដេចៗឲ្យលែងរាំទៅ ហើយទ្រង់ឲ្យហៅទាំងប្រុសទាំងស្រី មកដល់ហើយទ្រង់សួរថា "នេះជាប្រពន្ធចៅឯងមែនឬ ?" ។ បុរសនោះក្រាបបង្គំទូលថា "មែន" ។ ទ្រង់មានព្រះបន្ទូលសួរទៅប្រុសជា សហាយនោះថា "ឯងបានទៅលួចដំបងចៅនោះមែនឬ ?" ។ សហាយនោះ ក្រាបបង្គំទូលថា "លួចមែន" ។ ទ្រង់ឱ្យទៅយកដំបងនោះមកឲ្យយកសហាយទាំងប្រុសស្រីនោះទៅដាក់ច្រវាក់ធ្វើទោស ។ បុរសជា

ម្ចាស់ដំបងថ្វាយបង្គំសូមទោស ហើយក៏ប្រគល់ទាំងផ្ទះសំបែង ទាំងប្រពន្ធទៅសហាយនោះទាំងអស់ដោយពុំខឹងអ្វីឡើយ ។ បុរសសហាយនោះអរណាស់ សំពះសូមទោសរួចវិលទៅវិញ ។ ឯបុរសម្ចាស់ដំបងថ្វាយដំបងទៅស្ដេច ហើយក្រាបលាទៅទៀត ស្ដេចឃាត់ក៏ពុំព្រម ទ្រង់មានព្រះបន្ទូលថា "ដំបងវាយឯងនេះថ្លៃណាស់" ទ្រង់ព្រះរាជានុញ្ញាតបីឃ្លាំងមាសប្រាក់ឲ្យបុរសនោះយកតាមចិត្ត ។ បុរសនោះរើសអស់ទាំងឃ្លាំងមាសប្រាក់អម្បាលនោះទៅ ឃើញកាំបិតបន្ទោះ១ចាស់ នៅក្រោមឃ្លាំង ក៏យកកាំបិតនោះនិងប្រាក់បន្តិចបន្តួចគ្រាន់តែចាយតាមផ្លូវ ហើយចូលទៅក្រាបថ្វាយបង្គំលាស្ដេចដើរចេញទៅទៀត ។ ស្ដេចពុំមានព្រះបន្ទូលអ្វីទេតែអស់នាហ្មឺនគេ ត្មះតិះដៀលបុរសនោះថា "ជាមនុស្សឆោត មាសប្រាក់មិនយក ទៅយកឯកាំបិតច្រេះស៊ី" ។

បុរសនោះដើរចេញពីនគរនោះ បានទៅនគរមួយដទៃទៀត ។ ចួនជាថ្ងៃមួយនោះ ស្ដេចនគរនោះទ្រង់មានព្រះបន្ទូលបង្គាប់សេដ្ឋីម្នាក់ថា "ព្រឹកស្អែកទ្រង់ទៅក្រសាលព្រៃ ឱ្យមហាសេដ្ឋីធ្វើរទេះមួយយ៉ាងល្អល្អះ ឱ្យឆ្លាក់ក្បាច់លាបលនឱ្យហើយឱ្យទាន់ក្នុងពេលព្រឹកស្អែកនេះ បើធ្វើពុំទាន់នឹងយកទោសស្លាប់ខ្លួន" ។ រីឯមហាសេដ្ឋីនោះធ្វើពុំទាន់ហើយ ពុំធ្វើរទេះបែរជាទៅធ្វើឯក្ដារមឈូសទៅវិញ ។

ថ្ងៃនោះ ចួនជាបុរសនោះដើរទៅឃើញមហាសេដ្ឋីនោះកំពុងធ្វើបុណ្យក៏សួរថា "ចុះលោកមានការអ្វីបានជាធ្វើបុណ្យមានក្ដារមឈូសផងដូច្នេះ?" ។ គេប្រាប់ថា "ស្ដេចឲ្យធ្វើរទេះមួយយ៉ាងល្អ ឱ្យទាន់ពេលព្រឹកនេះ ស្ដេចនឹងទៅក្រសាលព្រៃ បើធ្វើពុំទាន់ស្ដេចនឹងយកទោសឥឡូវនេះ មហាសេដ្ឋីធ្វើពុំទាន់ ដឹងខ្លួនថាស្លាប់ បានជាធ្វើមឈូសធ្វើបុណ្យវិញ" ។

បុរសនោះឆ្លើយថា "ក្រអ្វីប៉ុណ្ណឹង ឱ្យតែបាយខ្ញុំស៊ី ខ្ញុំនឹងធ្វើឲ្យៗទាន់ព្រឹកនេះ" ។ មហាសេដ្ឋីបានឮដូច្នេះ អរណាស់ ហើយឲ្យរៀបបាយទឹកស៊ីឆ្អែតរួចប្រគល់ឈើឲ្យធ្វើរទេះ ។ បុរសនោះក៏ធ្វើតែនឹងកាំបិតមួយដែលយកក្រោមបាតឃ្លាំងនោះបានរួចស្រេចក្នុងយប់នោះ ហើយលាបលនយ៉ាងល្អព្រឹកឡើងក៏អូសទៅថ្វាយស្ដេចៗទ្រង់ទតឃើញទ្រង់ឲ្យរៀបប្រដាប់ប្រដាទៅក្រសាលព្រៃ ។ ឯមហាសេដ្ឋី លុះរួចពីស្លាប់ហើយក៏នឹកក្នុងចិត្តថា "អ្នកនេះមានគុណធ្ងន់ណាស់ ឥឡូវនេះនឹងរកអ្វីឲ្យសងឲ្យស្មើគ្មាន មានតែកូនក្រមុំ១ ល្អឲ្យមានប្ដី ដូច្នេះមានតែអញការឲ្យអ្នកនោះ" គិតហើយក៏ហៅមកការឲ្យទៅ ។ លុះការហើយក្នុងយប់នោះពេលផ្សំដំណេក បុរសនោះគិតល្បងចិត្តប្រពន្ធហើយធ្វើជាផឹកស្រាស្រវឹងដេកទៅ  យប់យូរបន្តិច ក៏ធ្វើជាក្អួតប្រឡាក់ប្រពន្ធអស់ ។ កូនសេដ្ឋីឃើញក្អួតប្រឡាក់ខ្លួនដូច្នេះ ក៏ស្រែកឡើងក្នុងយប់នោះថា "លោកឪពុករកប្ដីឲ្យខ្ញុំ ជាមនុស្សប្រមឹក ក្អួតប្រឡាក់ខ្ញុំអស់ហើយ ខ្ញុំទ្រាំមិនបានទេ" ។ មហាសេដ្ឋីឮកូនស្រែកដូច្នេះក៏ឃាត់ទៅថា "កូនដេកទៅ កុំនិយាយដ្បិតប្ដីកំពុងស្រវឹង ហើយគេមានគុណផង" ឃាត់ដូចម្ដេចក៏មិនស្ដាប់ថា "បើឲ្យទៅឆ្អែតឆ្អាទ្រាំបាន ឯមនុស្សប្រមឹកខ្ញុំទ្រាំមិនបានទេ" ។

លុះព្រឹកឡើងបុរសនោះរលឹកពីដេក ក៏ចូលទៅរកសេដ្ឋីប្រគល់កូនឱ្យវិញ ប្រាប់ថា "មិនព្រមយកទេ" ហើយថាមិនបានប៉ះដៃជើងឡើយ ។ មហាសេដ្ឋីឃាត់សុំទោសឱ្យកូន ក៏បុរសនោះពុំព្រមនៅ ពុំព្រមយក ហើយលាមហាសេដ្ឋីយកតែកាំបិតដើរទៅទៀត ។ លុះស្ដេចយាងមកពីព្រៃទ្រង់ឱ្យទៅរកជាងដែលធ្វើរទេះនោះពុំឃើញទ្រង់ស្ដាយណាស់ទ្រង់ឲ្យអស់នាហ្មឺនចាត់សំបុត្ររកគ្រប់ខែត្រក៏ពុំឃើញ ហើយទ្រង់នៅស្ងៀមទៅ ។

ឯបុរសនោះលាសេដ្ឋីដើរទៅឆ្ងាយ ក៏បានទៅដល់នគរមួយដទៃទៀត ។ ស្ដេចនគរនោះទ្រង់ឲ្យនាហ្មឺនម្នាក់ទៅដេកវេនចាំយាមនៅ ចុងព្រះរាជរោងរាល់យប់ ។ ស្ដេចទ្រង់ចេញកាប់តែរាល់យប់ ចាប់តាំងពីថ្ងៃដែលទ្រង់បង្គាប់មកនោះ ស្លាប់អស់នាហ្មឺនជាច្រើន ។

ថ្ងៃបុរសនោះទៅដល់ចួនត្រូវលើវេនចៅហ្វាទៅដេកថ្វាយស្ដេចកាប់ ចៅហ្វានោះក៏ធ្វើបុណ្យទានថ្ងៃនោះ ។ បុរសនោះទៅដល់សួរគេថា "លោកមានការអ្វី បានជាធ្វើបុណ្យទាន ហើយម្ដេច ក៏កូនប្រពន្ធយំរាល់គ្នាដូច្នេះ ?" ។ គេប្រាប់ថាលោកត្រូវទៅ

ដេកវេនថ្វាយស្ដេចកាប់ ល្ងាចនេះ បានជាលោកធ្វើបុណ្យមុនស្លាប់ ។ បុរសនោះថា "ឱ្យតែបាយខ្ញុំស៊ីចុះ ខ្ញុំទៅដេកថ្វាយស្ដេចជួស" ។ គេឮដូច្នេះក៏ទៅជំរាបចៅហ៊្វាៗឱ្យហៅបុរសនោះទៅ ឱ្យរៀបបាយទឹកស៊ីហើយសួរថា "បើអ្នកទៅដេកវេនថ្វាយស្ដេចជួយខ្ញុំៗនឹងធ្វើបុណ្យឱ្យអ្នក" បុរសនោះក៏ទទួលដេកជួយហើយសុំគ្រឿងប្រដាប់ ចៅហ៊្វាពាក់ នោះយកមកពាក់ ហើយក៏លីកាំបិតបន្ទោះ ចូលទៅដេក ចុងព្រះរាជវាំងចាំស្ដេចចេញមកកាប់ ។ ទៅដល់ចុងព្រះរាជវាំង បុរសនោះពុំដេកឡើយចាំស្ដេចចេញមកកាប់ ។ ទៅដល់ចុងព្រះរាជវាំង បុរសនោះពុំដេកឡើយ ចាំស្ដេចពេលយប់ជ្រៅស្ងាត់ ស្ដេចទ្រង់បើកទ្វារចេញមក ទ្រង់កាន់ព្រះខ័ន យាងចូលមក នឹងកាប់បុរសនោះ ។ បុរសនោះឃើញស្ដេចយាងមកជិត ក៏ស្ទុះចូលទៅចាប់ស្ដេចជាប់ ហើយក៏ចាក់នឹងកាំបិតបន្ទោះបង្កុស ពីរបីដង ហើយសួរថា "នរណា! ចូលមកទាំងយប់? ស្ដេចទ្រង់ឲ្យអញចាំយាមក្នុងយប់នេះ" ថាហើយក៏ចាក់បង្កុសទៀត ។ ស្ដេចទ្រង់មានព្រះបន្ទូលថា "ទេ! អញទេ!" ។ "នរណា! អញទេ ?" ។ "អញជាស្ដេច" ។ "ស្ដេចអីមកពេលនេះ ? អញមិនដឹងទេ! ដ្បិតស្ដេចទ្រង់ឲ្យអញចាំព្រះរាជវាំងក្នុងយប់នេះ" ។

សួរដេញដោលដូច្នេះហើយបុរសក៏លត់ជង្គង់ថ្វាយបង្គំស្ដេច សូមទោស ។ ស្ដេចត្រាស់សួរថា "ចៅនៅឯណា ?" ។ បុរសនោះថា "ខ្ញុំនៅផ្ទះចៅហ៊្វា" ។ ស្ដេចទ្រង់ជ្រាបទ្រង់ញញឹម ហើយទ្រង់ចូលទៅក្នុងវិញ ។

លុះព្រឹកឡើងបុរសនោះលីកាំបិត ចេញពីក្នុងវាំងមកផ្ទះចៅហ៊្វា ។ អ្នកផងឃើញឆ្ងល់ថា "បុរសនោះទៅដេកវេនថ្វាយស្ដេចកាប់ម្ដេចក៏មិនស្លាប់ត្រឡប់ជាមកវិញ?" ។ ចៅហ៊្វាសួរបុរសនោះជំរាបតាមដំណើរសព្វគ្រប់ហើយ ជម្រាបថែមទៀតថា "ស្ដេចសព្វថ្ងៃនេះមិនមែនជាកាចទេ ដ្បិតទ្រង់ពិសោធន៍រកមនុស្សចេះដឹងក្នុងនគរ ដើម្បីរក្សាស្ដេច បានជាទ្រង់ចាត់មនុស្សឲ្យយាម ទៅយាមចេះតែដេកលក់ ទើបស្ដេចទ្រង់កាប់ចុះបើសត្រូវវាចូលទៅលុកលុយស្ដេច ហើយយើងដេកលក់នោះ តើនឹងជាយ៉ាងណាទៅ ?" ។ បុរសនោះនិយាយ រឿងប្រាប់សព្វគ្រប់ ទើបភ្ញាក់ខ្លួនរាល់គ្នា ។

ចៅហ៊្វានោះមានកូនក្រមុំមួយ ក៏ឲ្យជាប្រពន្ធបុរសនោះ ដោយគិតថាបុរសនោះមានគុណធ្ងន់ណាស់ ។

លុះព្រឹកឡើងស្ដេចទ្រង់ឲ្យហៅបុរសនោះមក ទ្រង់ឱ្យធ្វើជានាហ្មឺនធំរក្សាព្រះនគរ បន្ទាប់ពីព្រះអង្គ ។

វេលាស្ដេចទ្រង់ព្រះជរាទៅ ទ្រង់ពុំមានព្រះរាជបុត្រ នឹងសោយរាជ្យស្នងមានតែព្រះរាជធីតាមួយអង្គ ក៏ទ្រង់ព្រះរាជទាន ព្រះរាជធីតា និងរាជសម្បត្តិឱ្យបុរសនោះសោយរាជ្យជាស្ដេចទៅ ។

## ពាក្យពិតមិនចេះស្លាប់